ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ៩៧/១៣-ម៉ាស្ទ័រ & ប្រ៊ែង
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ម៉ាស្ទ័រ & ប្រ៊ែង ខេមបូឌា ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិអង្គស្នួលទី៣ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០៩២ ២២៨ ១៥៨ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖ **អវត្តមាន**

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ - **សហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា**

- **សហជីពសាមគ្គីភាពការងារកម្ពុជា នៃក្រុមហ៊ុន ម៉ាស្ទ័រ & ប្រ៊ែង**

អាសយដ្ឋាន ៖ ភូមិអង្គស្នួលទី៣ ឃុំពើក ស្រុកអង្គស្នួល ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១៧ ៧២ ៨៤ ៧២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖ **អវត្តមាន**

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- សូមឱ្យក្រុមហ៊ុនទទួលយកថ្នាក់ដឹកនាំសហជីពសាមគ្គីភាពការងារកម្ពុជា ប្រចាំក្រុមហ៊ុនទាំងប្រាំបីនាក់ចូលធ្វើការជាធម្មតាវិញ ។

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

២- សូមឱ្យក្រុមហ៊ុនតម្លើងប្រាក់ខែគោល ចំនួន ២០ ដុល្លារ បន្ថែមទៀត លើប្រាក់ខែគោលដែលមានស្រាប់ ជូនដល់កម្មករ កម្មការិនី និងបុគ្គលិកទាំងអស់ ដោយរក្សាប្រាក់រង្វាន់លើកទឹកចិត្ត ចំនួ ៨ ដុល្លារ ដដែល ។

៣- ស្នើសុំឱ្យក្រុមហ៊ុនបន្ថែមលុយថ្លៃឡាន ចំនួន ១០ ដុល្លារទៀត គឺស្មើនឹង ១៧ ដុល្លារ ។

៤- ស្នើលុយបាយថ្ងៃត្រង់ ចំនួន ១៦ ដុល្លារ ជូនដល់កម្មករម្នាក់ៗ ក្នុងមួយខែ រៀងរាល់ខែ ។

៥- ចំពោះការសម្រាកការងារចំនួនពីរម៉ោង កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៣ ដើម្បីប្រារពពិធីជប់លៀងមុនថ្ងៃបុណ្យចូលឆ្នាំខ្មែរកន្លងទៅនោះ ស្នើសុំកុំឱ្យក្រុមហ៊ុនកាត់ប្រាក់ឈ្នួល និងប្រាក់រង្វាន់ផ្សេងៗ ។

៦- ចំពោះការព្រមានដល់កម្មករដែលប្រព្រឹត្តខុស ស្នើមិនឱ្យក្រុមហ៊ុនកាត់ប្រាក់រង្វាន់លើកទឹកចិត្តរបស់ពួកគាត់ចំនួនពីរដុល្លារឡើយ ។

៧- ចំពោះប្រាក់រង្វាន់ដែលកម្មករខំដេរបានក្នុងក្រុម តាមចំនួនផលិតផលប្រចាំថ្ងៃនោះ សូមឱ្យក្រុមហ៊ុនបើកជូនពួកគាត់តាមការជាក់ស្តែង ។

៨- សូមឱ្យក្រុមហ៊ុនបញ្ឈប់ការប្រើកាតទៅបន្ទប់ទឹក និងម៉ាស៊ីនស្កេនមេដៃ ពេលទៅបន្ទប់ទឹក និងពេលទៅហូបបាយ ។

៩- ស្នើសុំឱ្យក្រុមហ៊ុនបើកទ្វារខាងក្រៅអាគារ ដើម្បីឱ្យកម្មករបានចូលទៅក្នុងបន្ទប់ទឹក បន្ទាប់ពីបាយថ្ងៃត្រង់រួច មិនត្រូវឱ្យពួកគាត់ឈររង់ចាំខាងក្រៅ រហូតដល់ម៉ោង ១១៖៤០ នាទី ទើបឱ្យចូលនោះទេ ។

១០- ក្រុមហ៊ុនមិនត្រូវផ្លាស់ប្តូរកម្មករ ពីផ្នែកមួយទៅផ្នែកមួយទៀត ដែលជាការងារខុសជំនាញ របស់គេតាមតែគោលការណ៍របស់ខ្លួននោះទេ ។

១១- ស្នើសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់បច្ចេកទេស ចំនួន ៣០ ដុល្លារ ដល់ផ្នែកជាងម៉ាស៊ីនដេរ ជាងភ្លើង ជាងផ្សារមេកន្ត្រៃ ជាងឈើ និងផ្នែកគ្រូពេទ្យឱ្យបានស្មើៗគ្នា ។

១២- ស្នើសុំឱ្យក្រុមហ៊ុនរៀបចំប្រាក់រង្វាន់ ជូនដល់ជាងម៉ាស៊ីនដេរប្រចាំក្រុមនីមួយៗ ឱ្យបានស្មើនឹងកម្មករក្នុងក្រុមនោះដែរ ។

១៣- ស្នើសុំឱ្យក្រុមហ៊ុនរៀបចំឱ្យមានប្រាក់រង្វាន់ដល់ផ្នែកតុកាត់តាមចំនួនខោអាវដែលកាត់បាន ។

១៤- ស្នើសុំឱ្យមានបុគ្គលិកពេទ្យនៅប្រចាំការរាល់ម៉ោងធ្វើការ និងការងារបន្ថែមម៉ោងរបស់កម្មករ ។

១៥- ក្រុមហ៊ុនមិនត្រូវប្រើកិច្ចសន្យារយៈពេលខ្លីនោះទេ គឺក្រុមហ៊ុនត្រូវប្រើកិច្ចសន្យាយ៉ាងតិច ចាប់ពី ៦ ខែឡើងទៅ ។

១៦- ក្រុមហ៊ុនមិនត្រូវរើសអើងសហជីពសាមគ្គីភាពការងារកម្ពុជា ប្រចាំក្រុមហ៊ុន តាមគ្រប់រូបភាពនោះទេ ។

១៧- ស្នើសុំឱ្យក្រុមហ៊ុនបើកប្រាក់ឈ្នួលយ៉ាងទៀងទាត់រៀងរាល់ថ្ងៃទី០៥ នៃខែនីមួយៗ ។

១៨- សុំឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ក្នុងរយៈពេលនៃការធ្វើកូដកម្មនោះ ។

THE ARBITRATION COUNCIL

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១២១ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ (អាណត្តិទី១០)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៣៥៦/១៣ កប/កណ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល )។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួម ចំនួន ១៨ ចំណុច បានទទួលលទ្ធផល គឺសះជាចំនួន ០៥ ចំណុច និងនៅសល់ចំនួន ១៣ ចំណុចទៀត ដែលភាគីទាំងពីរចរចាបន្តទៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ ទៀត។ នៅថ្ងៃទី ០៧ និងទី០៨ ខែឧសភា ឆ្នាំ២០១៣ បន្តការផ្សះផ្សាចំនួន ១៣ ចំណុច ដែលនៅសល់ ដោយទទួលបានការសះជាចំនួន ០៥ ចំណុចទៀត។ សរុបមក ភាគីទាំងពីរបានសះជានឹងគ្នាចំនួន ១០ ចំណុច និងមិនសះជានឹងគ្នាចំនួន ០៨ ចំណុច។ ប៉ុន្តែ ភាគីកម្មករនិយោជិត ដើរចេញពីតុចរចា និងមិនព្រមបន្តការចរចាទៀតទេ។ ដូចនេះ ភាគីនិយោជកបានប្រកាន់ជំហរដាច់ខាតទៅលើលទ្ធផលសះជា ទាំង ១០ ចំណុច កន្លងមកក្លាយជាមោឃៈទាំងស្រុង ដោយចាត់ទុកមិនសះជាទាំង ១៨ ចំណុចវិញ។

ចំណុចមិនសះជាចំនួន ១៨ ចំណុច ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣ តាមរបាយការណ៍មិនសះជាលេខ ៣៥៦/១៣ កប.កណ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ ហើយលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១៨ ចំណុចនេះ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល។ ប៉ុន្តែ ភាគីកម្មករនិយោជិត និងនិយោជកមិនបានចូលរួមសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាដូចខាងក្រោម ៖

THE ARBITRATION COUNCIL

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតរបស់ក្រុមហ៊ុន ម៉ាស្ទ័រ & ប្រែហ្វុង (ខេមបូឌា) ខូអិលធីឌី គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្អាកការធ្វើកូដកម្មនៅក្រុមហ៊ុន ម៉ាស្ទ័រ & ប្រែហ្វុង (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត** ៖ គ្មាន

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ម៉ាស្ទ័រ & ប្រែហ្វុង (ខេមបូឌា) ខូអិលធីឌី លេខ ៣៥៦/១៣ កប/កណ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ម៉ាស្ទ័រ & ប្រែហ្វុង (ខេមបូឌា) ខូអិលធីឌី ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៥០៣ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៥០៤ កប/អក/វក/លកអ. ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទ ដែលចែងនៅក្នុងរបាយការណ៍មិនសះជារបស់នាយកដ្ឋានវិវាទការងារ ដែលបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារភាគីកម្មករនិយោជិត និងភាគីនិយោជក មិនបានអញ្ជើញមកចូលរួមសវនាការទេ ហើយក៏មិនបានផ្តល់នូវមូលហេតុសមរម្យណាមួយឡើយ។ ពោលគឺអវត្តមានដោយគ្មានមូលហេតុ។

**ហេតុផលនៃសេចក្តីសម្រេច**

តាមប្រការ ២១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"*។

បន្ថែមពីនេះទៀត វិធាន ៤.៧ នៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងឧបសម្ព័ន្ធនៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"*។

ផ្អែកលើប្រការ ២១ និងវិធាន ៤.៧ ខាងលើនេះ នៅក្នុងសេចក្តីបង្គាប់លេខ ៣០/០៥-មូរៀ, លេខ ១៦/០៧- ឡូទូសគី, លេខ ២៧/០៧-អ៊ីម និង វ៉េ ៣, លេខ ៩៥/០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន, លេខ ១៥១/០៨-វិល សិន, លេខ ០៩/០៩-នីមបឺស ថិចថាយ៍ លេខ ០១/១០-ខិននីតិច, លេខ ៣០/១០-ក្លូប័ល អាប៉ារែល ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញ មុនពេលដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ។ លក្ខខណ្ឌទី២ គឺភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីមិនបានផ្តល់មូលហេតុសម្រាប់ការមិនបង្ហាញខ្លួន។

ដូច្នេះ នៅក្នុងសំណុំរឿងនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើលក្ខខណ្ឌទាំងបីត្រូវបានបំពេញដែរឬទេ?

**លក្ខខណ្ឌទី ១ ៖ *ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ***

ដូចដែលបានបញ្ជាក់ក្នុងវិធាន ៤.៧ ខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងករណីអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្នុងករណីដែលភាគីវិវាទត្រូវបានជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរកឃើញថា លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើលិខិតអញ្ជើញជាផ្លូវការ (ជាលាយលក្ខណ៍អក្សរ) ទៅកាន់ភាគីនិយោជក លេខ ៥០៣ កប/អក/វក/លកអ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣ និង ទៅកាន់ភាគីកម្មករនិយោជិត លេខ ៥០៤ កប/អក/វក/លកអ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៣។ លិខិតអញ្ជើញទាំងនេះ ត្រូវបានធ្វើឡើងតាមនីតិវិធីជាប្រចាំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទំនាក់ទំនងទៅកាន់ភាគីទាំងពីរអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃថ្ងៃសវនាការតាមរយៈលិខិតអញ្ជើញជាលាយលក្ខណ៍អក្សរ និងតាមរយៈទូរស័ព្ទ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីទាំងពីរត្រូវបានជូនដំណឹងដោយត្រឹមត្រូវពីសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចនេះ លក្ខខណ្ឌទី១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ ៖ *ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ***

ប្រការ ១៩ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា

*"ភាគីវិវាទអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

បន្ថែមពីនេះទៀត ប្រការ ២០ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ក៏បានចែងថា *"ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ..... ភាគីទាំងនេះ ត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយ ដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"* ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត និងភាគីនិយោជកមិនបានមកចូលរួមសវនាការ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាង (ដូចជាខាងសហព័ន្ធសហជីព ឬមេធាវី) ដើម្បីតំណាងពួកគេនៅក្នុងសវនាការនោះទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ។

**លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ដូចដែលបានបញ្ជាក់ក្នុងប្រការ ២១ នៃប្រកាសខាងលើ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ក្នុងករណីភាគីបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ។

ក្នុងករណីនេះ នៅថ្ងៃសវនាការ ភាគីទាំងពីរមិនបានមានវត្តមាន។ នៅថ្ងៃសវនាការដដែល ភាគីនិយោជកបានទូរស័ព្ទមកកាន់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយបានជូនដំណឹងថា ភាគីទាំងពីរបានព្រមព្រៀងគ្នាចំពោះចំណុចវិវាទទាំងអស់នេះហើយ ប៉ុន្តែ រហូតមកដល់ថ្ងៃចេញសេចក្តីបង្គាប់នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានទទួលលិខិតលាយលក្ខណ៍អក្សរ ជាផ្លូវការណាមួយពីភាគីនៅក្នុងបញ្ចប់ ឬ ដកសំណុំរឿងនេះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិត និងភាគីនិយោជកអវត្តមាននៅថ្ងៃសវនាការ និងមិនបានផ្តល់មូលហេតុត្រឹមត្រូវណាមួយដល់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល អំពីការមិនចូលរួមសវនាការនោះទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ៩៧/១៣-ម៉ាស្ទ័រ & ប្រែហ្វូង នេះ ដោយភាគីកម្មករនិយោជិត និងភាគីនិយោជកអវត្តមាននៅពេលសវនាការ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

**សម្រេច និង បង្គាប់**

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ **៩៧/១៣-ម៉ាស្ទ័រ & ប្រែហ្វូង** ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ឹង សុទ្ធី**

ហត្ថលេខា ៖ ------------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អាន វីរៈ**

ហត្ថលេខា ៖ ------------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ------------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL